**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អធិដ្ឋានពេញមួយយប់នៅភាម៉ែល**
**ថ្ងៃទី០៦ កក្កដា ២០១៧**

| |
|---|
| អត្ថបទទី១៖កណ ២២,១-១៩<br>ដំណឹងល្អ៖មថ ៩,១-៨ |

បងប្អូនជាទីស្រឡាញ់!

យប់នេះដោយសម្លឹងមើលព្រះកាយព្រះគ្រីស្ត យើងយកពេលដើម្បីអរព្រះគុណព្រះជាម្ចាស់ ដែលណែនាំឲ្យយើងមានជីវិតអស់កល្បជានិច្ច ដោយសារព្រះបន្ទូលរបស់ព្រះគ្រីស្ត ដោយសារព្រះកាយព្រះគ្រីស្ត យើងដឹងថាជីវិតរបស់យើងមិនដូចពីមុន។ បងប្អូនដែលទទួលព្រះវិញ្ញាណដ៏វិសុទ្ធ គឺទទួលព្រះវិញ្ញាណដ៏វិសុទ្ធផ្ទាល់របស់ព្រះជាម្ចាស់ ដែលណែនាំឲ្យយើងមានកម្លាំងថែមទៀត មានសេចក្តីសង្ឃឹមថែមទៀត និងជាពិសេសមានប្រាជ្ញាឈ្លៀសវៃតាមព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះអង្គ។ ដូច្នេះនៅពេលនេះយើងនៅស្ងៀមស្ងាត់ដោយអរព្រះគុណព្រះជាម្ចាស់អស់ពីដួងចិត្ត ដោយសារព្រះអង្គប្រទានជីវិត ព្រះអង្គប្រទានសេចក្តីសង្ឃឹម ព្រះអង្គគង់នៅជាមួយយើងជានិច្ច ដើម្បីឲ្យយើងធ្វើដំណើរនៅក្នុងកាលៈទេសៈដែលមានអំណរដែលមានទុក្ខលំបាក ដែលមានសេចក្តីសង្ឃឹមដែលមានការព្រួយចិត្ត ដោយសារនៅពេលនោះ យើងដឹងថាព្រះយេស៊ូគង់នៅ ព្រះវិញ្ញាណដ៏វិសុទ្ធសន្ថិតលើយើង និងព្រះបិតាថែរក្សាយើងជានិច្ច។ អាម៉ែន៕